**អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍**

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

# សុន្ទរកថា

## ឯកឧត្តមទេសរដ្ឋមន្ត្រី អៀង មូលី ប្រធានអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ ថ្លែងក្នុងឱកាសបិទ សន្និបាតអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ ប្រចាំឆ្នាំ២០២៤

**ថ្ងៃព្រហស្បតិ៍ ៦រោច ខែកត្តិក ឆ្នាំរោង ឆស័ក ពុទ្ធសករាជ ២៥៦៨**

**ថ្ងៃទី២១ ខែវិច្ឆិកា ឆ្នាំ២០២៤**

**នៅទីស្តីការគណៈរដ្ឋមន្ត្រី**

- សូមគោរពអង្គពិធីទាំងមូល
- ឯកឧត្តម លោកជំទាវថ្នាក់ដឹកនាំអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍
- ឯកឧត្តម លោកជំទាវប្រធានគណៈកម្មាធិការប្រយុទ្ធនឹងជំងឺអេដស៍ក្រសួង រដ្ឋលេខាធិការដ្ឋាន រាជធានី ខេត្ត និងកាកបាទក្រហមកម្ពុជា
- ឯកឧត្តម លោកជំទាវ លោក លោកស្រី នាងកញ្ញា ភ្ញៀវជាតិ និងអន្តរជាតិជាទីរាប់អាន!

ឆ្លងកាត់ការបង្ហាញពីវឌ្ឍនភាព ប្រសិទ្ធភាព និងសមិទ្ធផល ជាពិសេសមេរៀនជាបទពិសោធន៍ល្អៗ ដែលបានមកពីការអនុវត្តរបស់សមាជិក សមាជិកា អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍នៅទូទាំងប្រទេសនៅក្នុងអង្គសន្និបាតនាពេលនេះ ក្នុងនាមអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ និងក្នុងនាមខ្លួនខ្ញុំផ្ទាល់ ខ្ញុំសូមសម្តែងនូវការអបអរសាទរ និងកោតសរសើរដ៏ស្មោះស្ម័គ្រចំពោះសមាជិក សមាជិកា នៃអង្គសន្និបាតទាំងអស់ ដែលបានខិតខំប្រឹងប្រែងយ៉ាងសកម្មចូលរួមការងារប្រយុទ្ធនឹងមេរោគអេដស៍ និងជំងឺអេដស៍ឱ្យទទួលបាននូវជោគជ័យជាបន្តបន្ទាប់គួរជាទីមោទនៈ។

***ឯកឧត្តម លោកជំទាវ អស់លោក លោកស្រី នាងកញ្ញា!***

លទ្ធផលដែលទទួលបានជាផ្លែផ្កាទាំងនេះ បានមកដោយសារមានក្របខណ្ឌគោលនយោបាយ យុទ្ធសាស្ត្រត្រឹមត្រូវ និងមានក្របខណ្ឌគតិយុត្ត រួមជាមួយក្របខណ្ឌស្ថាប័នបង្កើតបាននូវបរិយាកាសគាំទ្រដល់ការឆ្លើយតបនឹងមេរោគអេដស៍ និងជំងឺអេដស៍សម្រាប់ក្រសួង ស្ថាប័នទាំងនៅថ្នាក់ជាតិ នៅថ្នាក់ក្រោមជាតិ អង្គការដៃគូជាតិ អន្តរជាតិ សង្គមស៊ីវិល បណ្តាញប្រជាជនគន្លឹះ និងបណ្តាញអ្នកផ្ទុកមេរោគអេដស៍។ ការដឹកនាំការបង្ការដល់ក្រុមប្រជាជនគន្លឹះ ផ្តល់នូវសេវាថែទាំ និងគាំទ្រដល់អ្នកផ្ទុកមេរោគអេដស៍ និងធ្វើការ

ក្នុងភាពជាដៃគូរវាងរាជរដ្ឋាភិបាល ដៃគូពាក់ព័ន្ធ និងអង្គការអន្តរជាតិដើម្បីពង្រឹងសហគមន៍តែមួយ ក្នុងការឆ្លើយតបនឹងមេរោគអេដស៍(community-led responses) ដោយឈរលើគោលការណ៍ "**មិនទុកនរណាម្នាក់ចោលដោយមិនបានទទួលការយកចិត្តទុកដាក់**" ដោយផ្អែកលើគោលការណ៍គ្រឹះ ក្នុងភាពជាអ្នកដឹកនាំនៅថ្នាក់ជាតិ និងសហគមន៍ និងភាពជាម្ចាស់អនុលោមទៅតាមគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព គោលនយោបាយជាតិ ហិរញ្ញប្បទានប្រកបដោយចីរភាព កិច្ចសហប្រតិបត្តិការជាពហុវិស័យ អន្តរាគមន៍ផ្អែកលើភស្តុតាង គណនេយ្យភាព និងតម្លាភាព។

កម្ពុជាបានប្តេជ្ញាចិត្តក្នុងការបញ្ចប់អេដស៍ ដែលជាការគំរាមកំហែងសុខភាពសាធារណៈ ដែលស្របនឹងគោលដៅទី៣នៃគោលដៅអភិវឌ្ឍប្រកបដោយចីរភាព (Sustainable Development Goals) ដោយធានាការរស់នៅប្រកបដោយសុខភាពល្អ និងបង្កើនសុខុមាលភាពសម្រាប់មនុស្សគ្រប់វ័យ និងសម្រេចបានអត្រាគ្របដណ្តប់សុខភាពជាសកល ដោយរួមបញ្ចូលការការពារហានិភ័យហិរញ្ញវត្ថុ (Financial risk protection) ក្នុងការទទួលបានសេវាថែទាំសុខភាពសំខាន់ៗប្រកបដោយគុណភាព ។

ថ្វីត្បិតវឌ្ឍនភាពក្នុងការឆ្លើយតបអេដស៍ទទួលបានលទ្ធផលល្អប្រសើរ ដែលកម្ពុជាស្ទើរតែឈានទៅសម្រេចបានគ្រប់គោលដៅ៩៥-៩៥-៩៥ ជាពិសេសការគ្របដណ្តប់ការថែទាំព្យាបាល និងប្រសិទ្ធភាពនៃការព្យាបាលដែលយើងសម្រេចបានខ្ពស់រហូតដល់៩៨ភាគរយ ក៏ការឆ្លើយតបមេរោគអេដស៍ និងជំងឺអេដស៍បានកំពុងជួបនឹងភាពប្រឈមមួយចំនួនដែលតម្រូវឱ្យយើងបន្តធ្វើអន្តរាគមន៍។ ភស្តុតាងចុងក្រោយបានបង្ហាញថាល្បឿនថយចុះនៃការឆ្លងមេរោគអេដស៍ថ្មី មិនលឿនគ្រប់គ្រាន់ក្នុងការបញ្ចប់ជំងឺអេដស៍នៅឆ្នាំ២០២៥ ដែលយើងបានកំណត់គោលដៅនៃការឆ្លងមេរោគអេដស៍ថ្មីត្រឹមចំនួន២៥០នាក់ក្នុងមួយឆ្នាំ។ មានការថយចុះនៃការឆ្លងថ្មីនៃមេរោគអេដស៍ក្នុងចំណោមស្ត្រី ប៉ុន្តែបែរជាមានការកើនឡើងក្នុងចំណោមបុរស។ ការឆ្លងថ្មីក្នុងចំណោមក្រុមបុរសរួមភេទជាមួយបុរស ក្រុមបុរសរកស៊ីផ្លូវភេទ ក្រុមស្ត្រីបំប្លែងភេទ ជាពិសេសក្នុងចំណោមយុវវ័យកំពុងមានការកើនឡើងគួរឱ្យព្រួយបារម្ភ។ បន្ថែមលើនេះ ការចម្លងមេរោគអេដស៍ពីម្តាយទៅកូនក៏នៅមានអត្រាខ្ពស់នៅឡើយផងដែរ។

***ឯកឧត្តម លោកជំទាវ លោក លោកស្រី នាងកញ្ញា!***

ក្នុងនាមជាប្រធានអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ ឆ្លងតាមការពិភាក្សាយ៉ាងផុសផុលនៅក្នុងអង្គសន្និបាតនាពេលនេះ ខ្ញុំសូមចូលរួមចំណែកផ្តល់នូវអនុសាសន៍មួយចំនួនដូចខាងក្រោម៖

១. ធានាឱ្យបាននូវចីរភាព និងភាពធន់នៃការឆ្លើយតបទៅនឹងមេរោគអេដស៍ និងជំងឺអេដស៍ គ្រប់លំដាប់ថ្នាក់ ទាំងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ពិសេស ក្នុង ឃុំ សង្កាត់ ទាំងអស់នៅទូទាំងប្រទេស និងធ្វើការបញ្ជ្រាប និងបញ្ចូលសកម្មភាពឆ្លើយតបមេរោគអេដស៍ និងជំងឺអេដស៍ ទៅក្នុងផែនការរួមរបស់ក្រសួង ស្ថាប័ន រាជធានី ខេត្ត ស្រុក ខណ្ឌ និងឃុំ សង្កាត់។

២. ពង្រឹង និងពង្រីកសេវាបង្ការ ធ្វើតេស្ត និងថែទាំព្យាបាលមេរោគអេដស៍ និងជំងឺអេដស៍រួមគ្នា ជាពិសេសក្រុមប្រឈម និងក្រុមយុវវ័យនៅតាមសហគមន៍ ដោយអនុវត្តការប្រើប្រាស់ស្រោមអនាម័យ១០០% វិធីលេបថ្នាំបង្ការជាមុននៅពេលមានការប្រព្រឹត្តិប្រឈមនឹងការឆ្លងមេរោគអេដស៍ (PrEP) វិធីលេបថ្នាំបង្ការក្រោយពេលមានការប្រព្រឹត្តិប្រឈមនឹងការឆ្លងមេរោគអេដស៍ (PEP) និងការធ្វើតេស្តរកមេរោគ

អេដស៍ដោយខ្លួនឯង (Self-HIV Testing) រួមនឹងការប្រើប្រាស់ឱសថប្រឆាំងមេរោគអេដស៍ឱ្យបានត្រឹមត្រូវ។

៣. អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ ត្រូវជានាឱ្យបាននូវការសម្របសម្រួលជាពហុវិស័យឆ្លើយតបនឹងមេរោគអេដស៍បានល្អ ដោយមានការចូលរួមប្រកបដោយបរិយាបន្ន ដោយមូលដ្ឋាន និងសហគមន៍ជាម្ចាស់ ផ្តោតលើប្រជាពលរដ្ឋជាធំ មានភាពធន់ និងមានចីរភាព។

៤. រក្សាស្រោមអនាម័យឱ្យមាននៅគ្រប់ទីកន្លែង និងគ្រប់ពេលវេលា ដែលត្រូវការប្រើប្រាស់ ប្រកបដោយគុណភាពខ្ពស់ និងបន្តលើកទឹកចិត្តដល់ក្រុមយុវវ័យដែលរួមភេទដូចគ្នាឱ្យទៅធ្វើតេស្តរកមេរោគអេដស៍ និងប្រើប្រាស់កម្មវិធីបង្ការការចម្លងមេរោគអេដស៍តាមរយៈការប្រើស្រោមអនាម័យ១០០% នៅរាល់ពេលរួមភេទជាមួយដៃគូផ្សេង។

៥. ធ្វើឱ្យប្រសើរឡើងនូវសុខុមាលភាពសង្គមសម្រាប់ក្រុមប្រជាជនគន្លឹះ និងអ្នកផ្ទុកមេរោគអេដស៍ និងបង្កើតបរិយាកាសអំណោយផលដល់ការទទួលបាននូវសេវាព្យាបាល និងថែទាំជំងឺអេដស៍ សេវាគាំទ្រសុខាភិបាលនានា ព្រមទាំងសេវាគាំទ្រផ្នែកច្បាប់ និងសង្គមផ្សេងទៀត ប្រកបដោយប្រសិទ្ធភាពសម្រាប់ក្រុមប្រជាជនគន្លឹះ និងអ្នកផ្ទុកមេរោគអេដស៍ ។

៦. សូមអំពាវនាវឱ្យមានការចូលរួមយ៉ាងសកម្ម និងគាំទ្រខ្លាំងក្លាដល់បុគ្គលិកសុខាភិបាល ក្រសួង និងស្ថាប័នពាក់ព័ន្ធ រដ្ឋបាលថ្នាក់ក្រោមជាតិ ដៃគូអភិវឌ្ឍន៍ អង្គការសង្គមស៊ីវិល ផ្នែកឯកជន ក្រុមប្រជាជនគន្លឹះ ដើម្បីធ្វើការជាមួយគ្នាដោយជិតស្និទ្ធ និងបំពេញឱ្យគ្នាទៅវិញទៅមក សំដៅឆ្ពោះទៅការបិទបញ្ចប់អេដស៍នាពេលខាងមុខ ។

***ឯកឧត្តម លោកជំទាវ អស់លោក លោកស្រី នាងកញ្ញា !***

ខ្ញុំមានសង្ឃឹមថា អនុសាសន៍ទាំងអស់ខាងលើនេះ នឹងអាចយកទៅប្រើប្រាស់ជាចលករក្នុងការអនុវត្តគម្រោងផែនការសកម្មភាពជាតិទូលំទូលាយ និងពហុវិស័យ ឆ្លើយតបទៅនឹងការរាលដាលមេរោគអេដស៍ និងជំងឺអេដស៍ក្នុងឆ្នាំខាងមុខ ឱ្យកាន់តែមានប្រសិទ្ធភាពខ្ពស់ថែមទៀត។

ជាទីបញ្ចប់ ខ្ញុំសូមប្រសិទ្ធពរជ័យជូនអង្គសន្និបាតទាំងមូល សូម ឯកឧត្តម លោកជំទាវ លោក លោកស្រី នាងកញ្ញា ភ្ញៀវជាតិ និងអន្តរជាតិទាំងអស់ ទទួលបាននូវសុខភាពល្អ និងសម្រេចបាននូវជោគជ័យថ្មីៗបន្ថែមទៀត នាឆ្នាំ២០២៥ ខាងមុខនេះ និងសូមប្រកាសបិទ “**សន្និបាតអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ ឆ្នាំ២០២៤**” ចាប់ពីពេលនេះតទៅ។

***សូមអរគុណ!***